គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក

BOARD OF DIRECTORS

1. លោក ធន សារាយ
Mr. THUN Saray
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

2. លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

3. លោក យឹម ប៉ូ
Mr. YIM Po អគ្គលេខាធិការ
និងជានាយក CCPCR

4. អ្នកស្រី ស៊ុន ចាន់សែន
Mrs. SUN Chansen សមាជិកា
និងជាប្រធាន KYA

5. លោក យ៉ង់ គិមអេង
Mr. YONG Kim Eng សមាជិក
និងជានាយក PDP-Center

6. លោក មុំ សារិន
Mr. MOM Sarin សមាជិកា
និងជានាយក HRCDO

7. អ្នកស្រី ទីវ សារាយេត
Ms. TIV Sarayet សមាជិកា
និងជាសហនាយិកា WMC

8. កញ្ញា សយ សារា វឌ្ឍនី
Miss. SAY Sara Vathany
សមាជិកា
និងជានាយិកា CWCC

9. លោក គឹម សុវណ្ណ
Mr. KIM Sovann សមាជិក
និងជានាយក VIGILANCE

10. នាយក LAC (NA)

11. នាយក KKKHRO (NA)

12. អ្នកស្រី ពឹង យក់ហៀប
Ms. PEUNG Yok Hiep សមាជិកា
ជាឥស្សរជន Dignitary

13. លោក សឺន សែត
Mr. SEN Set សមាជិក
ជាឥស្សរជន Dignitary

ស.ប្រ.ក.ព/លេខ ០៥/១០ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# លទ្ធផលវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ក្នុងខេត្ត រតនគិរី

*ភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១០*

ម្ចាស់ឆ្នោតនៅខេត្តរតនគិរីប្រមាណ ៨0នាក់ ក្នុងនោះមានស្ត្រី ១0នាក់ (១២%) មកពីសហគមន៍ជនជាតិភាគតិច ព្រៃឈើ ដីធ្លី........ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ ដែលមកពីស្រុក/ក្រុងផ្សេងៗគ្នាក្នុងខេត្តរតនគិរី បានបង្ហាញពីការពេញចិត្តទៅលើការបំពេញការងារមន្ត្រីជាប់ឆ្នោត ក្នុងការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តរតនគិរី បើទោះបីជាលក្ខខណ្ឌទាំងនេះត្រូវបាន អនុវត្ត/បំពេញតិចតួចក៏ដោយ ។

ម្ចាស់ឆ្នោតភាគច្រើនបានធ្វើការវាយតម្លៃ ដោយផ្តល់ជាពិន្ទុចំពោះការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនីមួយៗនៅចន្លោះមិនបានធ្វើទាល់តែសោះ ដូចជាកុំយកកងកំលាំងប្រដាប់អាវុធជាតិទៅបំរើផលប្រយោជន៍បុគ្គល មិនត្រូវយកប្រាក់នៅពេលសួរសុខទុក្ខអ្នកទោសក្នុងពន្ធនាគារ ការបង្កើតរោងចក្រធុនតូច និងការកសាងសាលាបឋមសិក្សា ២ខ្នង នៅស្រុកអូរយ៉ាដាវ និងក្រុងបានលុងជាដើម ។

ចំណែកចំនុចដែលម្ចាស់ឆ្នោតមានការពេញចិត្តគឺទាក់ទងការកសាងផ្លូវដែលម្ចាស់ឆ្នោតបានផ្តល់ពិន្ទុនៅចន្លោះពីបានធ្វើពាក់កណ្តាល ទៅបានធ្វើច្រើន ។

សមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **សុខ ហម** បានមានប្រសាសន៍ថា នឹងលើកយករាល់បញ្ហា [ដែលនៅមិនទាន់បានបំពេញ/អនុវត្ត ] ដាក់ក្នុងប្រជុំក្រុមប្រឹក្សា ហើយសន្យាថានឹងជួយពិនិត្យមើលឡើងវិញ ។

ឯកឧត្តម **ម៉ុម សារឿន** អភិបាលរងខេត្តរតនគិរីបានលើកឡើងទាក់ទងនឹងការយកកំលាំងប្រដាប់អាវុធជាតិទៅបំរើក្រុមឯកជនមួយក្តាប់តូចថា នេះគឺជាការខុសពីគោលការណ៍ ហើយអាជ្ញាធរពុំបានដឹងរឿងទាំងនេះទេ ។

ការវាយតម្លៃនេះ ម្ចាស់ឆ្នោតធ្វើការផ្តល់ពិន្ទុទៅលើការបំពេញ/សម្រេចបានទៅលើចំនុចនីមួយៗដែលម្ចាស់ឆ្នោតបានធ្វើការទាមទារកាលពីឆ្នាំ២០០៩ ដោយឱ្យពិន្ទុ "ពិន្ទុ១ សំរាប់ការមិនបានធ្វើទាល់តែសោះ ឬបានធ្វើតិចតួច (ច្រើនបំផុតត្រឹម ២០%)" "ពិន្ទុ២ សំរាប់ការបានធ្វើខ្លះ (២១%-៤០%)" "ពិន្ទុ៣ សំរាប់ការបានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល (៤១%-៦០%)" "ពិន្ទុ៤ សំរាប់ការបានធ្វើច្រើន (៦១%-៨០%)" និង "ពិន្ទុ៥ សំរាប់ការបានធ្វើស្ទើរតែទាំងស្រុង ឬបានធ្វើទាំងស្រុង (៨១%-១០០%)"។

ជាលទ្ធផល ម្ចាស់ឆ្នោតបានផ្តល់ពិន្ទុទៅលើការសម្រេចបានរបស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗ ដែលម្ចាស់ឆ្នោតបានកំណត់កាលពីឆ្នាំ២០០៩ ដូចខាងក្រោម:

| **លទ្ធផលនៃការវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការសម្រេចបាន របស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗនៃលក្ខខណ្ឌសន្ធស្សន៍នៃវិស័យអាទិភាពនាំងជប់នៅក្នុងខេត្តរតនគិរី** |
|---|
| ១) រាជរដ្ឋាភិបាលត្រូវបង្កើតច្បាប់ប្រឆាំងអំពើពុករលួយឱ្យបាននៅយ៉ាងយូរត្រឹមថ្ងៃទី ០១ ខែ០១ឆ្នាំ ២០១០ហើយត្រូវ អនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធិភាព ដោយជនណាប្រព្រឹត្តផ្ទុយនឹងច្បាប់ប្រឆាំងអំពើពុករលួយត្រូវផ្តន្ទាទោសតាមច្បាប់ ដោយមិនរើសអើងទៅលើឋានៈបុណ្យសក្តិ ហើយត្រូវបង្កើតគណៈកម្មាធិការឯករាជ្យប្រឆាំង អំពើពុករលួយ នៅដើមឆ្នាំ ២០១០ ដែរ ។<br>ពិន្ទុ **១ (១៩%)** ពិន្ទុ **២ (៣៩%)** ពិន្ទុ **៣ (២១%)** ពិន្ទុ **៤ (១២%)** ពិន្ទុ **៥ (៩%)** |
| ២) ចាប់ពីដើមឆ្នាំ ២០១០ សុំកុំយកកងកំលាំងប្រដាប់អាវុធជាតិ ទៅបំរើផលប្រយោជន៍ក្រុមឯកជនមួយក្តាប់តូច ឬជនមានអំណាច ប្រើប្រាស់គំរាមកំហែងប្រជាពលរដ្ឋ កម្មករ ហើយរាល់បញ្ហា ដែលកើតមានឡើងជាមួយប្រជាពលរដ្ឋ ត្រូវដោះស្រាយដោយសន្តិវិធី និងតាមច្បាប់ដែលមានស្រាប់ ។<br>ពិន្ទុ **១ (៣៩%)** ពិន្ទុ **២ (៣៣%)** ពិន្ទុ **៣ (១៩%)** ពិន្ទុ **៤ (៥%)** ពិន្ទុ **៥ (៤%)** |
| ៣) ចង់ឱ្យមន្ត្រីកសិកម្មចុះបង្រៀនពី វិធីចិញ្ចឹមមាន់ ទា គោ ជ្រូក (១ ឆ្នាំ ៣ ដង : ខែ ០១ ខែ ០៤ ខែ ០៩ ចាប់ពីឆ្នាំ២០១០) នៅភូមិ ណងឡិ ឃុំអូរជុំ ស្រុកអូរជុំ ភូមិកំផ្លិញ ឃុំល្បាំង ស្រុកលំផាត់ ភូមិ ៣ ត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី ។<br>ពិន្ទុ **១ (១៥%)** ពិន្ទុ **២ (៣៤%)** ពិន្ទុ **៣ (៣០%)** ពិន្ទុ **៤ (១៤%)** ពិន្ទុ **៥ (៨%)** |
| ៤) តុលាការមិនត្រូវយកប្រាក់ពីប្រជាពលរដ្ឋក្រីក្រដែលជាជនរងគ្រោះ នៅពេលពួកគាត់ដាក់ពាក្យបណ្តឹងចូលតុលាការ ចាប់ពីដើមឆ្នាំ ២០១០ តទៅ ហើយរាល់ការទៅសួរសុខទុក្ខអ្នកទោស ក្នុងពន្ធនាគារមិនត្រូវយកប្រាក់ឡើយចាប់ពីដើមឆ្នាំ២០១០ តទៅ ។<br>ពិន្ទុ **១ (៦៣%)** ពិន្ទុ **២ (១៨%)** ពិន្ទុ **៣ (១០%)** ពិន្ទុ **៤ (៤%)** ពិន្ទុ **៥ (៥%)** |
| ៥) កសាងផ្លូវពីទីរួមស្រុកលំផាត់ ទៅភូមិបាតាង ឃុំបាតាង ស្រុកលំផាត់ ប្រភេទថ្មល់កៅស៊ូ ឱ្យរួចរាល់នៅឆ្នាំ ២០១១ ។ ថ្មល់ចាក់កៅស៊ូ ពីស្រុកបានលុង ទៅភូមិតាស៊ុយ ឃុំកាចាញ ឱ្យហើយ នៅឆ្នាំ ២០១១ ។ ស្រុកអូរយ៉ាដាវ ដល់ ភូមិគងធំ ឃុំបាតេ ឱ្យហើយត្រឹមឆ្នាំ ២០១១ ក្រាល កៅស៊ូ ។ ផ្លូវចូលភូមិពីផ្លូវធំ (ផ្លូវ ៧៨) ទៅភូមិ ឡាអិន ឃុំ តឺនស្រុកកូនមុំ ប្រវែង ៥០០ ម៉ែត្រ ក្រាលគ្រោះ ឬកៅស៊ូ ឱ្យហើយត្រឹម ឆ្នាំ ២០១១ ។ ផ្លូវគ្រោះ ឬកៅស៊ូ ពីផ្លូវជាតិចូលភូមិយ៉ឺន ឃុំកក់ ស្រុកបរកែវ ៥០០ ម៉ែត្រ ។<br>ពិន្ទុ **១ (៥%)** ពិន្ទុ **២ (២៥%)** ពិន្ទុ **៣ (៣៦%)** ពិន្ទុ **៤ (២៧%)** ពិន្ទុ **៥ (៧%)** |

| |
|---|
| ៦) សង់សាលារៀនបឋមសិក្សាថ្មី (៦ បន្ទប់) នៅភូមិ តាអង ថ្នាក់បឋមសិក្សា ឱ្យរួចរាល់នៅឆ្នាំ ២០១១ ។ សង់សាលារៀនបឋមសិក្សា (៤ បន្ទប់) នៅភូមិកាឡៃ សាពូន ឃុំភ្នំកុក ស្រុកវើនសៃ —សាលារៀនមតេយ្យ មួយ នៅភូមិ ១ ឃុំកាចាញ ឱ្យរួចរាល់នៅឆ្នាំ ២០១២ ។ សង់សាលារៀនបឋមសិក្សា (៥ បន្ទប់) នៅភូមិសាលា ឃុំកក់ ស្រុកបរកែវ និងមណ្ឌលសុខភាព (សំណង់ថ្មប្រក់ក្បឿង) នៅឃុំត្រពាំងក្រហម ឱ្យរួចរាល់នៅឆ្នាំ ២០១២ និងមណ្ឌលសុខភាពនៅឃុំ តាអង នៅឆ្នាំ ២០១១ ។ ជំរុញការកសាងផ្សារស្រុកកូនមុំ នៅឃុំត្រពាំងច្រេស (សំណង់ថ្ម) ឱ្យហើយនៅឆ្នាំ ២០១០ ។<br>ពិន្ទុ **១ (១៨%)** ពិន្ទុ **២ (២០%)** ពិន្ទុ **៣ (៤៤%)** ពិន្ទុ **៤ (១៧%)** ពិន្ទុ **៥ (១%)** |
| ៧) សុំអោយមន្ត្រីកសិកម្មចុះបង្រៀនរបៀបចិញ្ចឹមជ្រូក និងសុំពូជជ្រូកមួយចំនួន (បង្រៀន ៣ ដង ក្នុងខែ 0១ ខែ 0៤ ខែ 0៧ និងសុំពូជជ្រូកយ៉ក់ខ្សៀ ចំនួន ៦0ក្បាល ញី ៤0 ឈ្មោល ២0 នៅភូមិកាឡៃ សាពូន ភ្នំកុក ឃុំភ្នំកុក ស្រុកវើនសៃ និងភូមិកាតេ ឃុំលុងខ្វ ស្រុកអូរយ៉ាដាវ ដោយសុំអោយមេភូមិជាអ្នកចែកអោយអ្នកដែលអត់ទាន់មាន ចាប់ពីឆ្នាំ ២0១0 ។<br>ពិន្ទុ **១ (២៨%)** ពិន្ទុ **២ (៣៤%)** ពិន្ទុ **៣ (២៨%)** ពិន្ទុ **៤ (៨%)** ពិន្ទុ **៥ (១%)** |
| ៨) សុំអោយមន្ត្រីពេទ្យសត្វចុះចាក់ថ្នាំ (គោ ក្របី) ២ ដង ក្នុងមួយឆ្នាំ ខែ0៦ និងខែ ១២ មានមន្ត្រីចុះមានគ្នា ៣ នាក់ ចាក់នៅគ្រប់ ស្រុក ចាប់ពីដើមឆ្នាំ ២0១0 ។<br>ពិន្ទុ **១ (៣២%)** ពិន្ទុ **២ (៣១%)** ពិន្ទុ **៣ (២៣%)** ពិន្ទុ**៤ (១0%)** ពិន្ទុ**៥ (៤%)** |
| ៩) សុំអោយបង្កើតរោងចក្រធុនតូច ចំនួន ៣ មានដូចជា រោងចក្រគ្រាប់ស្វាយចន្ទី រោងចក្រកែច្នៃម្សៅមី និងរោងចក្រកែច្នៃសណ្តែកសៀង នៅទីរួមខេត្តរតនគិរី យ៉ាងយូរ ឆ្នាំ ២០១២ ។<br>ពិន្ទុ **១ (៣៦%)** ពិន្ទុ **២ (២៣%)** ពិន្ទុ **៣ (២២%)** ពិន្ទុ **៤ (១៤%)** ពិន្ទុ **៥ (៥%)** |
| ១០) សុំសាលាបឋមសិក្សាចំនួន ២ ខ្នង (មួយខ្នងនៅភូមិ ១ ក្រុមតាស៊ុយ ឃុំកាចាញ ស្រុកបានលុង ។ មួយខ្នងទៀត នៅភូមិកងយុ ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ ឱ្យបានក្នុងឆ្នាំ ២០១០)<br>ពិន្ទុ **១ (៥0%)** ពិន្ទុ **២ (២៣%)** ពិន្ទុ **៣ (១៦%)** ពិន្ទុ **៤ (១0%)** ពិន្ទុ **៥ (១%)** |
| ១១) **ចំនុចរួម: តើអ្នកពេញចិត្តការអនុវត្តន៍របស់មន្ត្រីជាប់ឆ្នោតចំពោះលក្ខខណ្ឌសន្ទស្សន៍ទាំង១០ កម្រិតណា?**<br>១) មិនពេញចិត្តទាល់តែសោះ, **(៧%)** ២) ពេញចិត្តតិចតួច, **(១៥%)** ៣) ពេញចិត្តគួរសម, **(៣៤%)** ៤) ពេញចិត្តច្រើន, **(២២%)** ៥) ពេញចិត្តទាំងស្រុង **(២៣%)** |

ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយម្ចាស់ឆ្នោតក្នុងវេទិកាម្ចាស់ឆ្នោតដែលរៀបចំដោយគណៈកម្មាធិការ **ខុមហ្វ្រែល** ដោយមានកិច្ចសហការជាមួយសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) នៅក្នុងខែមិថុនា។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*


- លោក **សុខ ពិន្ទុរឿ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: 0៨៩ ៥២៥ ៤៤៦